# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ខែកក្កដាឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០០៣

Downloaded from http://www.khmerlaws.com

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់សមាសភាពនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគណនេយ្យដែលមានអក្សរកាត់ **ក.ជ.គ** ដែលស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២.-**

**ក.ជ.គ** មានភារកិច្ច :

-ធ្វើជាអង្គការពិគ្រោះយោបល់

-ពិនិត្យនិងផ្តល់យោបល់លើរាល់គម្រោងច្បាប់និងបទបញ្ជានានា ដែលមានបទប្បញ្ញត្តិទាក់ទងទៅនឹងការរៀបចំកិច្ចការគណនេយ្យសម្រាប់រាល់សហគ្រាស ឬសកម្មភាពសេដ្ឋកិច្ច

-រៀបចំក្របខ័ណ្ឌទស្សនទាននិងស្តង់ដារគណនេយ្យ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និង វិជ្ជាជីវៈគណនេយ្យ

-ស្នើឡើងនូវមធ្យោបាយសម្រាប់កែលំអបច្ចេកទេសគណនេយ្យ

-ធ្វើជាតំណាងព្រះរាជាណាចក្រកម្ពុជានៅក្នុងអង្គការអន្តរជាតិនិងនៅក្នុងកិច្ចប្រជុំដើម្បីជជែកវែកញែកអំពី គណនេយ្យ ។

## ជំពូកទី ២

## សមាសភាពនិងការជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យ

**មាត្រា ៣.-**

**ក.ជ.គ** មានសមាជិកចំនួន ១៣ រូប :-

- តំណាងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ៣ រូប
- តំណាងរបស់ក្រសួងយុត្តិធម៌ ចំនួន ១ រូប
- តំណាងរបស់ធនាគារជាតិនៃកម្ពុជា ចំនួន ២ រូប
- សមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករខ្មែរ ចំនួន ៣ រូប

Downloaded from http://www.khmerlaws.com

- សាស្ត្រាចារ្យឧត្តមសិក្សាដែលបង្រៀនមុខវិជ្ជាគណនេយ្យ សវនកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចំនួន ១ រូប
- តំណាងរបស់ក្រសួងពាណិជ្ជកម្ម ចំនួន ១ រូប
- អ្នកទទួលបន្ទុកគណនេយ្យហិរញ្ញវត្ថុនៃសហគ្រាស ស្នើដោយសភាពាណិជ្ជកម្ម ចំនួន ២ រូប ។

តំណាងរបស់ក្រសួង ស្ថាប័នដែលជាសមាជិក ក.ជ.គ ខាងលើ លើកលែងតែតំណាងរបស់ក្រសួងយុត្តិធម៌ ត្រូវមានជំនាញគណនេយ្យ និង បទពិសោធន៍យ៉ាងតិច ៥ ឆ្នាំ ។

**មាត្រា ៤.-**

ប្រធាន អនុប្រធាន និង សមាជិក **ក.ជ.គ**ត្រូវបានតែងតាំងសំរាប់រយៈពេល៣ ឆ្នាំ ហើយអាចតែងតាំងសារជាថ្មីសំរាប់រយៈពេល ៣ឆ្នាំម្តងទៀត ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បើសមាជិកណាម្នាក់ក្នុងអាណត្តិរបស់ខ្លួន ត្រូវផ្លាស់ប្តូរដោយមូលហេតុណាមួយ អ្នកដែលមកជំនួសត្រូវបានតែងតាំងសំរាប់រយៈពេលដែលនៅសល់នៃអាណត្តិនោះ ។

**មាត្រា ៥.-**

តំណាងក្រសួង ស្ថាប័ន ត្រូវអស់សិទ្ធិជាសមាជិក **ក.ជ.គ** ក្នុងករណីដែលតំណាងនោះលាឈប់ពីសមាជិក **ក.ជ.គ** ឬឈប់បម្រើការងារក្នុងក្រសួង ស្ថាប័នសាមី ។

អនុលោមទៅតាមបទបញ្ជាផ្ទៃក្នុង សមាជិក **ក.ជ.គ** ដែលមានសំលេង ៣/៤ អាចសុំរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បញ្ឈប់សមាជិកណាម្នាក់របស់ខ្លួន ដែលមិនបានចូលរួមប្រជុំក្នុង **ក.ជ.គ** ។

**មាត្រា ៦.-**

ប្រធាន និងអនុប្រធាន **ក.ជ.គ** ត្រូវបានជ្រើសរើសក្នុងចំណោមសមាជិក **ក.ជ.គ** តាមវិធីបោះឆ្នោតជាសម្ងាត់ដែលមានសម្លេងភាគច្រើនដាច់ខាត ដែលកោះប្រជុំក្រោមអធិបតីភាពនៃសមាជិកដែលមានវ័យចាស់ជាងគេ ។ ការតែងតាំងប្រធាននិងអនុប្រធាន ត្រូវបានធ្វើឡើងក្នុង រយៈពេលមួយខែបន្ទាប់ពីថ្ងៃដែលបានជាប់ឆ្នោត ។

ប្រធាន និង អនុប្រធានអាចត្រូវបានបញ្ឈប់ពីតំណែងដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ។ អនុប្រធានមានសិទ្ធិជំនួសប្រធាន ក្នុងពេលអវត្តមានបណ្តោះអាសន្នរបស់ប្រធាន ។

Downloaded from http://www.khmerlaws.com

ក្នុងករណីដែលប្រធានមិនអាចបំពេញការងារបានតទៅទៀត អនុប្រធានត្រូវឡើងជាប្រធានដោយស្វ័យប្រវត្តិ ។ ការជ្រើសរើសអនុប្រធានថ្មី ត្រូវអនុវត្តតាមបែបបទដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រា៦នេះ ។

## ជំពូកទី ៣
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាជាតិគណនេយ្យ

**មាត្រា ៧.-**

**ក.ជ.គ** ត្រូវប្រជុំក្រោមអធិបតីភាពរបស់ប្រធានយ៉ាងតិច ៣ដងក្នុងមួយឆ្នាំ ដើម្បីអនុម័តលើគំរោងយោបល់ ក្របខ័ណ្ឌទស្សនទាន ស្តង់ដារគណនេយ្យ ស្តង់ដារសវនកម្ម អនុសាសន៍ កម្មវិធីការងារប្រចាំឆ្នាំ និងគំរោងរបាយការណ៍សកម្មភាព ។

កូរ៉ុមដែលអាចឱ្យ **ក.ជ.គ** ដំណើរការប្រជុំបានត្រូវមានវត្តមានសមាជិកយ៉ាងតិចចំនួន ៥រូប ។ ក្នុងការសំរេចផ្សេងៗ **ក.ជ.គ** ត្រូវមានសម្លេងពាក់កណ្តាលបូកមួយនៃសមាជិកវត្តមាន ។

ប្រធានកោះហៅ និង ជាអធិបតីភាពនៃអង្គប្រជុំ **ក.ជ.គ** ។ ក្នុងករណីមានការបែងចែកសម្លេងស្មើគ្នា សម្លេងប្រធានមានឧត្តមានុភាព ។

ក្នុងករណី **ក.ជ.គ** សំរេចលើគំរោងច្បាប់ ឬបទបញ្ញា ស្តង់ដារគណនេយ្យ ស្តង់ដារសវនកម្ម ដែលទាក់ទងនឹងផ្នែកសកម្មភាពណាមួយ រដ្ឋមន្រ្តីដែលជាអាណាព្យាបាលនៃផ្នែកនេះ ត្រូវមានតំណាង ហើយតំណាងនេះចូលរួមដោយមានសម្លេងសំរេច ។ ចំពោះមតិលើគំរោងច្បាប់ និងគម្រោងបទបញ្ញានានាដែល **ក.ជ.គ**បានទទួល **ក.ជ.គ** ត្រូវពិនិត្យ និងសំរេចក្នុងរយៈពេល ៦ខែ ចាប់ពីថ្ងៃតាមបញ្ជារបស់រដ្ឋមន្រ្តីដែលមានសមត្ថកិច្ច ។

សេចក្តីសំរេចរបស់ **ក.ជ.គ** ត្រូវបានបញ្ជូនទៅរដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងរយៈពេលមួយខែក្រោយពីថ្ងៃសំរេច ។

**មាត្រា ៨.-**

**ក.ជ.គ** អាចបង្កើតគណៈកម្មការដើម្បីពិនិត្យ និង ផ្តល់មតិលើគំរោងយោបល់ក្របខ័ណ្ឌទស្សនទាន ស្តង់ដារគណនេយ្យ ស្តង់ដារសវនកម្ម ឬអនុសាសន៍ ។

សមាជិកគណៈកម្មការ ដែលមកពីបណ្តាក្រសួង ស្ថាប័ន និងពីមជ្ឈដ្ឋានធុរៈកិច្ចទាំងឡាយ ត្រូវតែងតាំងដោយប្រធាន **ក.ជ.គ** ក្រោមការស្នើសុំរបស់ **ក.ជ.គ**។

Downloaded from http://www.khmerlaws.com

គណៈកម្មការអនុម័ត ដោយភាគច្រើនធម្មតា នៃអ្នកវត្តមាននូវគំរោងយោបល់ ក្របខ័ណ្ឌទស្សនទាន ស្តង់ដារគណនេយ្យ ស្តង់ដារសវនកម្ម ឬអនុសាសន៍ ។ ក្នុងករណីមានការបែងចែកសម្លេងឆ្នោតស្មើៗគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាព ។

**មាត្រា ៩.-**

ប្រធាន **ក.ជ.គ** ជាតំណាងក្នុងការទាក់ទងជាមួយក្រសួង ឬ ស្ថាប័ននានា និង សង្គមស៊ីវិលឯកជន ជាតិ ឬអន្តរជាតិ ។

ប្រធាន **ក.ជ.គ** ធ្វើរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ក.ជ.គ** ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលត្រូវរាយការណ៍បន្តជូនរាជរដ្ឋាភិបាល ក្នុងរយៈពេលបួនខែក្រោយបំណាច់ឆ្នាំ បរេណីទីមួយៗ ។

**មាត្រា ១០.-**

បែបបទនៃការផ្តល់លាភការសំរាប់មុខតំណែងរបស់សមាជិក **ក.ជ.គ** ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១១.-**

**ក.ជ.គ** មានលេខាធិការដ្ឋានមួយ ដឹកនាំដោយលេខាធិការមួយរូបដែលត្រូវបានបង្កើត និងតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីបានពិគ្រោះយោបល់ជា មួយ **ក.ជ.គ** ដោយសម្លេងភាគច្រើន ។

**មាត្រា ១២.-**

មុខតំណែងលេខាធិការនៃ **ក.ជ.គ** មានវិសមិតភាពជាមួយមន្ត្រីក្របខ័ណ្ឌសាធារណៈ ឬវិជ្ជាជីវៈឯកជនដែលកំពុងអនុវត្តកិច្ចការគណនេយ្យ ។ ក្រោមការគ្រប់គ្រងរបស់ប្រធាន **ក.ជ.គ** លេខាធិការទទួលបន្ទុកការគ្រប់គ្រងរដ្ឋបាលនៃ **ក.ជ.គ** រៀបចំ និងតាមដានការងារបច្ចេកទេស និងរាល់បញ្ហាដែលប្រធានឬ **ក.ជ.គ** ប្រគល់ឱ្យ ។ លេខាធិការចូលរួមប្រជុំជាមួយ **ក.ជ.គ** ដោយគ្មានសំលេងសំរេច។ បែបបទនៃលាភការសំរាប់លេខាធិការ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៣.-**

បទបញ្ជាផ្ទៃក្នុងនៃ **ក.ជ.គ** និងការរៀបចំលេខាធិការដ្ឋាន ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ** អនុម័តដោយសំលេង ៣/៤ នៃចំនួនសមាជិក ។

Downloaded from http://www.khmerlaws.com

**មាត្រា ១៤.-**

ថវិការបស់ **ក.ជ.គ** មានប្រភពមកពី :-

-ថវិការដ្ឋ

-វិភាគទាន. អំណោយ និងជំនួយពីអង្គការសាធារណៈ អង្គការជាតិ និងអន្តរជាតិ

-ផលនៃអនុប្បទានដែលបានមកពីការលក់សិទ្ធិអ្នកនិពន្ធ ការបោះពុម្ពផ្សាយ ពីការបើកវគ្គហ្វឹកហ្វឺនបណ្តុះបណ្តាល ការប្រជុំផ្សព្វផ្សាយ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០០៣

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អាជ្ញាធរសវនកម្មជាតិ
-ដូចមាត្រា ១៥
-ឯកសារ - កាលប្បវត្តិ



Downloaded from http://www.khmerlaws.com